# តារាងគុណតម្លៃនៃជំនាន់ស៊ី (Génération C) នៅប្រទេសកម្ពុជា

ដើម្បីចូលរួមក្នុងចលនា“ ជំនាន់ស៊ី (Génération C) នៅប្រទេសកម្ពុជា” ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានអានការបង្ហាញគុណតម្លៃនេះ ហើយខ្ញុំធ្វើការចែករំលែករាល់ខ្លឹមសារទាំងអស់ដែលមានចែងនៅក្នុងនេះ។

ខ្ញុំសូមប្រកាសនូវការប្រកាន់ខ្ជាប់របស់ខ្ញុំចំពោះការភ្ញាក់រលឹកខ្លួននិងស្មារតីសមូហភាពដោយចាប់ផ្តើមចេញអំពីការយល់ដឹងនិងមនសិការដែលខ្ញុំមានចំពោះខ្លួនឯង។

ខ្ញុំប្តេជ្ញាប្រឆាំងនូវរាល់គ្រប់រូបភាពអណ្តែតត្រសែតនៃភាពអាត្មានិយមរបស់ខ្ញុំ ដោយកំចាត់ចោលនូវភាពលោភលន់ឥតព្រំដែនដែលកប់នៅក្នុងខ្លួនខ្ញុំ ហើយបែរមកផ្តោតលើការរួមរស់នៅជាមួយគ្នាជាសមូហភាព។

ខ្ញុំប្តេជ្ញាប្រកាន់ជំហរទៀងត្រង់ដោយប្រកាន់យកតួនាទីសង្គមដែលតម្រូវឱ្យខ្ញុំពង្រឹងខ្លួនឯងបង្កើនភាពស្ងប់ស្ងាត់ ភាព មនុស្សធម៌ ភាពរលូន ភាពសាមញ្ញ ភាពដាក់ខ្លួន ក្តីមេត្តាករុណាភាពអស្ចារ្យនៃដួងព្រលឹង សេរីភាព ភាពអំណត់ ភាពស្មោះត្រង់ ភាពសប្បុរស ភាពរាបសារនិងការស្វាគមន៍យ៉ាងកក់ក្តៅដល់អ្នកដទៃ ។

ខ្ញុំត្រូវធ្វើខ្លួនឯងអោយដូចជាកញ្ចក់ដើម្បីផ្តល់ពន្លឺឆ្លុះបញ្ចាំងដល់អ្នកដទៃ ហើយត្រូវមានក្រមសីលធម៌ និងមានសោភ័ណតំលៃ ដើម្បីផ្តល់ជាគំរូល្អដល់ពួកគេ។

ខ្ញុំត្រូវលើកតម្កើងជីវិតរបស់ខ្ញុំនិងជីវិតអ្នកដទៃ ហើយក៏ត្រូវធ្វើវាអោយក្លាយទៅជាចំណែកនៃស្នាដៃសិល្បៈដែលខ្ញុំបានរក្សាទុកសំរាប់ជានិមិត្តរូបនៃប្រាជ្ញា ការអោណិតអាសូរ និងភាពថ្លៃថ្នូរនៅលើផែនដីនេះផងដែរ។

ខ្ញុំប្រកាន់ខ្ជាប់នូវគោលការណ៍ដែលថាភាពសំបូរបែបដ៏អស្ចារ្យរបស់យើងគឺពួកយើងជាពលរដ្ឋនៅក្នុងពិភពលោកយើង ហើយពួកយើងក៏ជាសមាជិកនៃជំនាន់ស៊ី (Génération C) ដែល

ដំបូងឡើយផ្តើមចេញពីទំនាក់ទំនងរវាងមនុស្សនិងមនុស្ស សាមគ្គីភាព ភាពអត់ធន់ និងការអាណិតអាសូរដែលកើតចេញពីក្នុងចិត្ត។

ខ្ញុំសូមសន្យាថានឹងនិយាយការពិតដោយគ្មានការភូតភរកុហក ដោយប្រើពាក្យពេជន៍ត្រឹមត្រូវនិងសមរម្យចំពោះអ្នកដទៃហើយគ្មានទំនោរតាម ជំនឿ តាមទស្សនៈនយោបាយ តាមប្រភពដើម តាមទំនោរភេទឬ តាមសម្ព័ន្ធភាពសង្គមណាមួយឡើយ។

ខ្ញុំប្តេជ្ញាបង្ហាញពីការយល់ចិត្តនិងភាពយុត្តិធម៌ ដោយជៀសវាងនូវរាល់ការជេរប្រមាថ ឬការរងរបួសចំពោះមនុស្សនិងសត្វ។

ខ្ញុំប្តេជ្ញាគោរពមនុស្សលោកក្នុងពិភពរបស់ពួកគេ ក្នុងភាពចម្រុះវប្បធម៌របស់ពួកគេ ក្នុងប្រភពដើមកំណើតរបស់ពួកគេ ក្នុងសមាជិកភាព និងពណ៌សម្បុរស្បែករបស់ពួកគេ។ ខ្ញុំយល់ថាយើងទាំងអស់គ្នាគឺស្ថិតក្នុងប្រភេទ Homo sapiens ដែលមានន័យថាជីវិតនិងអនាគតរបស់យើងគឺមិនស្ថិតស្ថេរទេនាពេលបច្ចុប្បន្ន ដូច្នេះអនាគតរយៈពេលមធ្យមក្តីនិងពេលវែងក្តី របស់យើងគឺពិតជាមិនប្រាកដប្រជាទេ។ នៅក្នុងបរិបទនេះ ខ្ញុំសូមប្រកាសខ្លួនថាក្នុងនាមខ្ញុំជាពលរដ្ឋនៅក្នុងពិភពលោកយើងនេះ ខ្ញុំនឹងធ្វើការចែករំលែកដល់ពិភពលោកនិងត្រលប់ខ្លួនមកក្លាយជាកម្មសិទ្ធិរបស់ភពតែមួយរួមគ្នាវិញ។

ខ្ញុំសូមប្រកាន់ខ្ជាប់នូវគោលការណ៍អភិរក្សធម្មជាតិ នេះមានន័យបញ្ជាក់ថាយើងមិនមែនជាចៅហ្វាយ ហើយក៏មិនមែនជាម្ចាស់នៃធម្មជាតិដែរ ប៉ុន្តែពួកយើងរួមរស់នៅតែមួយជាមួយនឹងធម្មជាតិ។

ខ្ញុំសូមប្រកាសអំពីទំនាក់ទំនង និងការប្រកាន់ខ្ជាប់របស់ខ្ញុំនូវគោលការណ៍នៃការគោរពនូវរាល់តុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី ដែលជាអ្នកបង្កើតមាតាធម្មជាតិ ហើយក៏ជាអ្នកផ្តល់ជំរកដល់មនុស្សយើងសំរាប់ពឹងពាក់ស្នាក់អាស្រ័យជានិរន្តរភាពផងដែរ។ ការស្វែងរកសុខុមាលភាពរបស់ខ្ញុំ មិនត្រូវបានបង្កមហន្តរាយដល់សុខុមាលភាពមាតាធម្មជាតិនោះទេ។

ដូច្នេះខ្ញុំប្តេជ្ញាយ៉ាងសកម្មក្នុងការការពារនិងគោរពបរិស្ថានរួមរបស់យើងដោយអស់ពីចិត្តពីថ្លើម។

ខ្ញុំប្រកាន់ខ្ជាប់ និងដឹកនាំនៅក្នុងជំនាន់ស៊ីកម្ពុជា (Génération C) ដើម្បីឆ្លុះបញ្ចាំងពីការស្រាវជ្រាវ និងការអនុវត្តតំលៃរួមដោយផ្អែកលើទស្សនវិជ្ជានៃសិល្បៈក្នុងការរស់នៅជាមួយគ្នា រួមបញ្ចូលនឹងចក្ខុវិស័យរួមនៃសង្គមរបស់យើងនៅពេលទទួលយកភាពខុសគ្នានិងចំណុចនៃទស្សនៈ។ សិល្បៈនៃភាពសហការរួមគ្នានឹងភាពសុខដុមព្រមទាំងភាពចម្រុះគ្នាដើម្បីទទួលបានការរស់នៅជាមួយគ្នាអោយបានប្រសើរជាងមុន។
ខ្ញុំប្តេជ្ញាចិត្តត្រិះរិះពិចារណាលើបញ្ហាប្រឈមនៃភពផែនដីដែលយើងជួបប្រទះមានដូចជា (ការបាត់បង់ធនធានធម្មជាតិ បញ្ហាអាកាសធាតុ វិបត្តិពិភពលោកបន្ទាប់ពីវត្តមានជំងឺរាតត្បាតកូវីដ គម្លាតនៃសង្គមនិងសេដ្ឋកិច្ច រួមទាំងការបាត់ខ្លួននៃភាវៈរស់។ ល។ ) អនាគតពិភពលោកនៅថ្ងៃអនាគត ត្រូវលើកកម្ពស់ពហុសកល ដែលអនុញ្ញាតឱ្យមានភាពចម្រុះនៃវប្បធម៌ សាសនា ឬទស្សនវិជ្ជាផ្សេងៗគ្នាដើម្បីធ្វើការផ្លោះប្តូរគំនិតពិភាក្សាគ្នាទៅវិញទៅមកធ្វើយ៉ាងណាគឺដើម្បីស្វែងរកផលប្រយោជន៍រួមអោយពលរដ្ឋកម្ពុជា ហើយមិនត្រូវហែកហួរគ្នានោះទេ។

ខ្ញុំសូមប្រកាសខ្លួនថា ការធ្វើសមាហរណកម្មនៃព្រះរាជាណាចក្រកម្ពុជានិងតួនាទីរបស់ប្រទេសយើង នៅក្នុងការរស់នៅក្នុងពិភពលោកសំរាប់ថ្ងៃអនាគតតាមរយៈអសនៈនៅក្នុងអង្គការសហប្រជាជាតិនិងនៅក្នុងស្ថាប័នអន្តរជាតិដទៃទៀត ក្នុងការគ្រប់គ្រងបញ្ហាអន្តរជាតិក្នុងការលើកកម្ពស់មុខមាត់ថ្មីរបស់ពលរដ្ឋលើឆាកអន្តរជាតិ។

ខ្ញុំសូមប្រកាសអំពីសារៈសំខាន់នៃតួនាទី និងការប្តេជ្ញាចិត្តយ៉ាងមុតមាំជាចាំបាច់របស់ខ្ញុំសំរាប់ពិភពលោកនៅថ្ងៃអនាគត។

ហត្ថលេខា                                                        កាលបរិច្ឆេទ